# លោកយាយង ប្លេនន

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



WRITTEN BY KAREN SHELTON FICHEROUX ILLUSTRATED BY ERICA ARTHUR



លោកយាយហ្វ្រេននីចូលចិត្តចាក់អំបោះណាស់។
សំឡេងម្ជុលចាក់គឺជាសេចក្ដីសុខរបស់លោកយាយ។





ខ្លីកខ្លាក់! ខ្លីកខ្លាក់! ពេលគាត់មើលទូរទស្សន៍!

ខ្លីកខ្លាក់! ខ្លីកខ្លាក់! ពេលគាត់និយាយជាមួយមិត្តភក្តិ!

ខ្លីកខ្លាក់! ខ្លីកខ្លាក់! ពេលគាត់ធ្វើដំណើរកម្សាន្ត!

ខ្លីកខ្លាក់! ខ្លីកខ្លាក់! ពេលគាត់អង្គុយរង់ចាំ!

ខ្លីកខ្លាក់! ខ្លីកខ្លាក់! គាត់ចាក់អំបោះដោយមិនចាំបាច់មើលម្ជុល!





គាត់បានចាក់អំបោះធ្វើជាមួក កន្សែង អាវនិងភួយ ដើម្បីទុកប្រើប្រាស់ក្នុងគ្រួសារដ៏កក់ក្ដៅរបស់គាត់។





លោកយាយហ្វ្រេននីបានសម្រេចចិត្តថាគួរដល់ពេលចាប់ផ្តើមជួយអ្នកដទៃហើយ។
អ្នកក្រីក្រ
អ្នកគ្មានផ្ទះសំបែង
អ្នករស់នៅតែម្នាក់ឯង
អ្នកដែលរងា
និងអ្នកត្រូវការភាពកក់ក្តៅ។





គាត់បានចាក់ហើយចាក់ទៀត ទាំងថ្ងៃទាំងយប់។ ខ្លីកខ្លាក់! ខ្លីកខ្លាក់!
រហូតបន្ទប់របស់គាត់ពោរពេញទៅដោយមួកនិងកន្សែងគួរឱ្យស្រលាញ់ដែលបាន
ផ្តល់នូវភាពកក់ក្តៅ។ មានទាំងមួកនិងកន្សែងធំ តូច ល្មម សម្រាប់ទារកតូចៗគ្រប
ដណ្តប់ដោយពណ៌តន្នធនូ។





លោកយាយហ្វ្រេននីបន្តការចាក់ ហើយចាក់ទៀត ទាំងថ្ងៃទាំងយប់។ ខ្លីកខ្លាក់! ខ្លីកខ្លាក់!
រហូតបន្ទប់របស់គាត់ពោរពេញទៅដោយតុក្កតាគួរឱ្យស្រលាញ់។
មានទាំងតុក្កតា ធំ តូច ល្មម សម្រាប់ទារកតូចៗគ្របដណ្ដប់ដោយពណ៌ឥន្ទធនូ។





លោកយាយហ្វ្រេនទីបានរៀបចំរបស់ទាំងនោះដាក់ចូលក្នុងវ៉ាលីដ៏ធំមួយដែលពោរពេញទៅ
ដោយមួក កន្សែងនិងតុក្កតាយ៉ាងណែនតាន់តាប់ស្ទើរតែផ្ទុះវ៉ាលីទៅហើយ។
គាត់បានផ្ញើរបស់ទាំងនោះទៅដល់អ្នកដែលត្រូវការពិតប្រាកដទីទាល់នៅតំបន់ដាច់ស្រយាល។





មនុស្សជាច្រើនបានទទួលអារម្មណ៍កក់ក្តៅនៅពេលប្រើ ហើយបានរក្សាកន្សែងនិង
តុក្កតាដ៏ស្រស់ស្អាតរបស់លោកយាយហ្វ្រេននីទាំងក្តីនឹករលឹក។
អ្នកទាំងនោះមិនធ្លាប់បានជួបលោកយាយហ្វ្រេននី ដូច្នេះហើយ មិនអាចនិយាយពាក្យ
អរគុណទៅកាន់គាត់ផ្ទាល់ទេ។





លោកយាយហ្វ្រេននីដឹងថា ការជួយមនុស្សធ្វើឱ្យមានក្តីសុខ ទើបគាត់បន្តចាក់អំបោះទៀត។ មិត្តភក្តិរបស់លោកយាយចង់ទទួលបានអារម្មណ៍រីករាយនិងការជួយមនុស្សដែរ ដូច្នេះពួកគាត់ចាប់ផ្តើមចាក់អំបោះជាមួយគ្នា។ ម្ជុលចាក់អំបោះជាច្រើនត្រូវបានធ្វើការយ៉ាងសកម្ម។ ខ្លីកខ្លាក់! ខ្លីកខ្លាក់! យើងរួមគ្នាដើម្បីជួយមនុស្សនៅក្នុងពិភពលោក។ អំឡុងពេលមិនយូរប៉ុន្មាន របស់ទាំងនោះត្រូវបានដាក់ចូលក្នុងវ៉ាលីរួចរាល់សម្រាប់ផ្ញើ។ អំបោះចាក់ចម្រុះពណ៌ជាច្រើនត្រូវបានជួយដល់មនុស្សក្នុងលោកឱ្យមានភាពកក់ក្តៅនិងរីករាយ។





លោកយាយហ្វ្រេននីបានចាក់ភួយជាច្រើន។ មានទាំងភួយធំ ហើយទន់កក់ក្តៅគួរឱ្យចង់
ដណ្តប់។ ភួយនីមួយៗសុទ្ធតែចាក់ដោយដៃជាច្រើន។ ខ្លីកខ្លាក់! ខ្លីកខ្លាក់!
ខ្លះមានរាងឆ្នូត ខ្លះមានរាងជាការ៉ូ។ ឯខ្លះទន់ដូចសំឡី ខ្លះមានសភាពទន់ទ្វេដងនិង
ខ្លះទៀតទន់ដូចរោមសត្វ។ គ្រប់ភួយទាំងអស់សុទ្ធតែជាពណ៌ចម្រុះស្រស់ឆើតឆាយនិង
មើលទៅកក់ក្តៅយ៉ាងខ្លាំង។





លោកយាយហ្រ្វេននីបានផ្តល់ភួយជាអំណោយជូនដល់អ្នកជំងឺនៅឯមន្ទីរពេទ្យ។
អ្នកដែលមានកូនតូច ចាស់ជរានិងអ្នកដែលត្រូវការក្តីស្រឡាញ់ពិតប្រាកដ។


G.F.



ទីណាមានភួយទីនោះតែងតែធ្វើឱ្យមនុស្សមានក្តីស្រឡាញ់និងភាពកក់ក្តៅ។ ភួយទាំងនោះបានធ្វើឱ្យពួកគេមានអារម្មណ៍សប្បាយរីករាយដូចមានមិត្តម្នាក់នៅក្បែរជានិច្ច។


GF



លោកយាយហ្វ្រេននីស្រឡាញ់ការចាក់អំបោះ។  គាត់គឺជាស្ត្រីសាមញ្ញម្នាក់នៅក្នុង
ពិភពលោកដ៏ធំធេងមួយនេះ។ យ៉ាងណាមិញ គាត់បានបង្ហាញឱ្យយើងឃើញថា មនុស្ស
ម្នាក់ៗអាចធ្វើឱ្យពិភពលោកមួយនេះមានភាពស្រស់បំព្រងបាន។


GF




# លោកយាយហ្វ្រេននី

គំនូរជីវចល

ធនធានបង្រៀន

Written by Karen Shelton Ficheroux

Illustrated by Erica Arthur

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

TUKTUK

Rotary